# ឧត្តមភរិយា

## បទព្រហ្មគីតិ



មាតិកា

ការឧទ្ទិស....2

ពន្លកស្នេហ៍ ....3

បំណះកាយ ....5

ស្ម័គ្រចិត្ត....9

ឧប្បត្តិហេតុ ....12

ប្រតិសន្ធិ....15

ឧប សៅ សន្ធា ការចងចាំ ២១ មេសា ២០២០

# ឧត្ដមភរិយា

## ការឧទ្ទិស

កំណាព្យនេះ សរសេរឧទ្ទិស ចំពោះ ខួប ទី ៣០ ឆ្នាំ នៃ អាពាហ៍ពិពាហ៍ របស់ខ្ញុំ និង ភរិយា នូវ សេចក្ដីស្នេហា របស់នាង ចំពោះ ស្វាមី ព្រមទាំង សេចក្ដីស្រឡាញ់រង្គំ របស់ខ្ញុំ ចំពោះ ពនិតា[1]។ នាង ជា ឧត្ដមភិយា និង ម្ចាស់ដួងចិត្ត របស់ប្ដី។ យើង រួមគ្នា កសាង គ្រួសារ នៅក្នុង សេចក្ដីសុខសាមញ្ញ តែ ពោរពេញ ទៅ ដោយ សុភមង្គល ថ្លៃថ្លា។ សម្រស់ និង ចិត្តផ្អែម របស់នាង ជា កម្លាំងតស៊ូ របស់ខ្ញុំ ក្នុង ឆាកជីវិតអន្លាយ ប្រកប ទៅដោយ ឧបសគ្គ គ្រប់បែបយ៉ាង។ ខ្ញុំ លើក កម្បង់អញ្ជលី សំពះ ព្រះ នូវ អស់ទេវតា គ្រប់ សាសន៍ជាតិ សូមឱ្យនាង ចាកផុតរោគ ចង្រៃ គ្មានលាប់ និង រក្សា ស្នេហ៍វិសុទ្ធ នៃ គូ ប្រណិពីធម្មជាតិ របស់ យើង ឱ្យបានគង់វង់ និង ផ្សង សូមជួប នាង គ្រប់ៗជាតិ។



ភួងផ្កាស្នេហ៍ចំពោះភរិយា

1 ពនិតា : ភរិយា។

# ឧត្តមនារិយា

## ពន្លកស្នេហ៍



សម្រស់ពីធម្មជាតិ

បងជួបស្រីជាផ្កា   មានចិន្តាស្នេហ៍លើស្ងួន
ជាវាសនាចងរួម   នៅក្នុងសួនជីវិតគ្រង។
នៅក្នុងច្បាប់ស្នេហា   មានតណ្ហាលើស្រីវង
ផ្គួបបាតដៃពីរគ្រង   សម្ពីប៉ងក្បង់ក្លិនខ្លួន។

គន្ធភាយក្នុងឱទ្យាន   ជាសួគ៌បានស្រីស្ងួន
គ្មានផ្កាណាអាចជូន   ជៀបក្នុងសួនបុស្បា។
ផ្កាអើយស្រឡាញ់ម្លេះ   ចង់តែបេះព្រោះប្រាថ្នា
ទុកជាគូស្នេហា   មានផ្កាស្លាជាសាក្សី។

ផ្តាំពាក្យតាមវាយោ   ថាចិត្តទោរចងភក្តី
ជាសច្ចៈមេត្រី   គូនឹងស្រីតាមទំនាយ។
ថាបងជួបទាវគន់   វាសនាកត់ទុកដូចទាយ
អូនបងជាគូព្រាង   មិនអាចរាងក្នុងជាតិនេះ។

# ឧត្តមតរិយា

ព្រហ្មលិខិតចងរួម ផ្គូរបង្រួមបង្រុះចិត្ត
អោយក្រងស្នេហ៍វិចិត្រ ស្នេហ៍ស្មោះចិត្តគ្មានអវសាន។
ស្រីបើកហ្វូរទ័យនាង ផ្ញើសំនៀងស្នេហ៍កំសាន្ត
ចិត្តបងឱ្យក្លាហាន នៅក្នុងឋានសែនសប្បាយ។

ព័ន្ធសីមាវាសនា ភូមិស្នេហាបដិលោម[2]
ចិត្តនិងចិត្តនៅក្រោម អំណាចឡោមសេចក្តីស្មោះ។
វាចាឆ្លើយតាមខ្យល់ នាំក្លិនគន់មានសម្រស់
សម្បូរស្រអែមស្រស់ ហោះមកប្រោះចិត្តចាញ់ស្នេហ៍។

រាមក្សង់បុណ្យព្រេងឈ្ងប់ ប្រចី[3]គល់សន្ទូចសាជ[4]
សាធុអោយចិត្តស្អាត សាធុផាត[5]ទទួលស្នេហ៍។
ពៅអើយកុំសង្ស័យ កែវចរណៃបងថ្នមថែរ
ថិរភាពគ្មានកែ ដូចដីស្រែនិងវារី។

រាមរង់ចាំស្រីថ្លៃ រៀងរាល់ថ្ងៃតាមសន្យា
មួយនាទីយឺតយាត្រា មកឃើយា[6]ដួងចិត្តបង។
រលឹកណាស់ប្អូនស្រី រាល់រាត្រីចិត្តតែងផ្សង

[2] បដិលោម : ជាបដិភាព, ទៅវិញទៅមក។
[3] ប្រចី : កិ. ទាក់ឆ្វាត់ផ្ទួងគល់ផ្លែសន្ទូច។
[4] សាជ : គុ. សម្រេចប្រយោជន៍។
[5] សាធុផាត : ល្អ, ដែលត្រឹមត្រូវ។
[6] ឃើយា : យាឃើ។

# ឧត្តមឥរិយា

ចង់ជួបស្រីជាហង្ស ចង់ត្រកងទេពធីតា។

ល្អនេះពេញល្អក្នុង សុបិនស្លុះក្នុងអារម្មណ៍
ចិត្តបងសែនបារម្ភ ខ្លាចសំណំស្នេហ៍របាយ។
ក្នុងពេលរង់ចាំអូន ខ្លាចបាត់សូន្យព្រោះឆ្ងាយកាយ
កាយនិងចិត្តនៅឆ្ងាយ ខ្វះឱបាយផ្ដាំរឭក។

សូមផ្ដាំតាមវាយោ គ្មានទោសោក្នុងចិន្ដា
ផ្ញើរលឹកគ្មានប្រេះឆា ប្រឱបផ្កាក្នុងសុបិន។
ស្រឡាញ់គ្មានសង្ស័យ គ្មានជលស័យ[7]ជម្រះក្លិន
គន្ធាទឹកអប់ផ្ដិត ក្នុងដួងចិត្តត្រៀមចាំពៅ។

## បំណះ[8]កាយ



សុភមង្គលពិមល

[7] ជលស័យ : ជលសា, សមុទ្រ។
[8] បំណះ : គូដែលប៉ះគ្នា។

# ឧត្តមភរិយា

យើងបានណាត់ជួបគ្នា   បំណះគ្រាកាយក្បែរកាយ

ឃើញភក្ត្របងសប្បាយ   ដូចទន្សាយឃើញព្រះខែ។

ហរទ័យស្នេហ៍អូនម្លឹង   ចិត្តលែងថ្លឹងច្បាប់ផ្ដាំផ្ដែ

ថាប្រុសត្រូវតែថៃ   កេរ្តិ៍នៅក្បែរពៅវិសុទ្ធ។

ស្រឡាញ់ឆោមនិងចិត្ត   កាយនៅជិតញវាថា

ពីរោះអ្វីស្រីណ៎ា!   ចិត្តណាស់សាចង់អោបពៅ។

កាលសិសិរៈមាស[9]   ពុំអាចពាសលើកំដៅ

ប្រាណនិងចិត្តហួងសៅ[10]   ប៉ងអោបពៅម្ចាស់ចិន្តា។

ពេលនិយាយថៅវ៉ៅ[11]   ចិត្តហាហៅហត្ថាបង

រំកិលដាក់តម្រង់   លើដៃស្រស់ចរណៃ។

រោលប្រឌិបហត្ថយើង   ពីលើភ្លើងស្នេហ៍ពេកក្រៃ

ព្រោះតែនួនល្អងថ្លៃ   ផ្ដល់តម្លៃជាអមតៈ។

[9] សិសិរមាស ៖ ខែរងាខ្លាំង។
[10] ចិត្តហួងសៅ ៖ ចិត្តផ្ដាំផ្ដួង។
[11] និយាយថៅវ៉ៅ ៖ និយាយរាយរកគ្នា។

# ឧត្តមភរិយា

ជលនេត្រក្នុងភ្នែក ដូចពេជ្ររែកពាក្យសន្យា
ថាអូនផ្តល់ស្នេហា ស្មើវេហានិងពសុធា
កែវភ្នែកស្រីផ្តាំបង អូននិងបងគូគ្នានពារ
ពុំមានចិត្តវេទនា រាសុរា[12]ចន្ទពេញបូណ៌។

ពៅអើយស្រីចំណាន បងក្លាហានស្រវាអោប
កាយវង់រាមក្រសោប ភ្ជាប់ទ្រូងឆោមថ្នក់វាសនា។
ផ្គួចផ្តើមចិត្តរវើយ ខ្យល់រំភើយខែរងា
អារម្មណ៍ជាទាសា ក្នុងស្នេហាស្រីជាម្ចាស់។

អូនបងក្នុងអកាល ហត្ថាស្រាលរបស់ពៅ
ព័ន្ធបងរោលចិត្តយៅវ៏[13] បងនិងពៅបានឆ្លងយុគ។
គ្មានដែនកំរិតកាល គ្មានទីឋានកំរិតសុខ
រំលងសុកលទុក្ខ លើវិសុទ្ធិមគ្គ[14]លោកីយ។

ពៅញញឹមដាក់បង ថ្ពាល់ផូរផង់សាយសម្រស់

---

[12] រាសុរា : រាត្រីកាល។
[13] យៅវ៏ : វ័យកំលោះឬក្រមុំ។
[14] មគ្គ : ផ្លូវ។

# ឧត្តមនារិយា

នាំឱ្យរាមស្រណោះ   សប្បុរសស្រីឧត្តម។
ញញឹមៗល្វន់  ខ្លួនទន់ភ្លន់ម្ចាស់តូចតន់
ហត្ថាបងតម្កល់   ពុំឱ្យសល់លើទ្រូងបង។

ភក្ត្រស្រអែមពិដោរ   ប្រហើរថ្ពាលទោសស្រែកក្លិន
សក់ស្រីផុកសៀតពិន[15]   ចិត្តបងមិនផុតរាគៈ[16]។
បបូរមាត់រាងរៀវ   រេរាំទាវស្តីរាក់ទាក់
ប្រាប់បងថាស្រីល័ក្ខណ៍  ពៅស្មោះស្ម័គ្រតែបងមួយ។

ថើបស្រីជាចម្លើយ   ចិត្តលំហើយដោយស័ព្ទស្នេហ៍
ថើបហើយថើបខំថែរ  សម្បថស្នេហ៍ឆ្លើយនឹងស្ងួន។
ក្លិនផ្កាម្លិះប្រហើរ   ពុំអាចស្មើថាអាចជូន
គន្ធបបូរមាត់នួន   នៅក្នុងសួនស្នេហាយើង។

---

15 ពិន : ស្នៀតសក់ផុក។
16 រាគៈ : សេចក្តីរីករាយ ឬ តម្រេក។

# ឧត្តមភរិយា

## ស្ម័គ្រចិត្ត



ទេពសប្បថ

រូបអូនជាតំណាង   វាសនាគ្រោងទុកពីអតីត
ត្រូវបានសំរេចគិត   ជាការពិតក្នុងជាតិនេះ។
ផ្កាស្លាចងមេត្រី   ជាភក្តីគ្មានចិត្តរិះ
ទឹកចិត្តយើងបែបនេះ   ជាជំនិះសាងជីវិត។

ភរិយាឧត្តម   ស្វាមីផ្សំចិត្តស្មោះត្រង់
ជាគូស្នេហ៍ត្រចង់   បង្កើតវង់រស្មីស្នេហ៍។
នាវាជីវិតចរ   តាមចំណរចិត្តគ្មានកែរ
រាល់ឆ្នាំរាល់ថ្ងៃខែ   យើងតែងតែនឹកថ្ងៃការ។



## ឧត្តមភរិយា

ជាខួបនៃមង្គល   ជាទ្រនំថ្នាលរស្មី
សុគតិក្នុងជីវិត   យើងដង្ខិត[17]សាងសួស្តី។
ជាគ្រឹះសមូហ:   មានសុរ:[18]គ្រកកភក្តី
កើតផ្កាកូនប្រុសស្រី   មានរូបិរថនាប័ទ្ម[19]។

ភរិយាចេះផ្គាប់   ជាទម្លាប់ដោយធម្មជាតិ
រវាំង[20]ច្បាររមានជាតុ   ជារុក្ខជាតិច្បាប់ស្ត្រី។
សន្សំជាប្រចាំ   មិនរាប់ឆ្នាំស្នេហ៍ស្វាមី
សញ្ជឹងសុខកូន-ប្ដី   គ្មានសម្តីឆ្គងសីលធម៌។

អប់រំអស់តនុជ[21]   ធម្មព្រះពុទ្ធផ្តាំថាត្រូវ
បដិបត្តិតម្រូវ   គ្មានសត្រូវព្យាបាទខ្លួន។
ពុំពាធជន្មសត្វលោក   នាំទុក្ខទោសមកគង្គួន
ប្រទាំងធម្មជាតិផ្ទួន   នាំឱ្យខ្លួនមានសៅហ្មង។

17 ដង្ខិន : ត្រិះរិះ, ជញ្ជឹង។
18 សុរ (សុរ:) : ទេព្តា។
19 រថនាប័ទ្ម : ក្បាច់រថនាឈូក ឬ បុទម។ ក្បាច់ត្របកឈូកភ្ញារ។
20 រវាំង : មើលថែទាំ, រក្សា។
21 តនុជ : កូនប្រុសស្រី។

# ឧត្តមភរិយា

ពៅសំណព្វចិត្តប្តី ! ជាស្រីអូនហ្នឹងហើយ
រួមហទ័យរួមខ្មើយ ជាចម្លើយអោយនិស្ស័យ។
បងជួបអូនជាគូ ជាគំនូរពិសម័យ
គួរព្រោះតែប្រស័យ[22] ស្នេហ៍អាស្រ័យ[23]បុណ្យអក្ខោ[24]។

វល្លកា[25]ចេះផ្គាប់ ឱ្យប្តីគាប់ចិត្តពុំល្ហែ
ជលី[26]បងអង្អែល កាយស្រីថែរស្នេហាយើង។
បិទស្បៃវត្សកន្លង បងត្រកងគ្មានភ្លោះភ្លើយ។[27]
កាយស្រីនួនល្មើយ[28] គឺហ្នឹងហើយឫសគល់ស្នេហ៍។

ចេះផ្គាប់ភក្សាហារ[29] គ្រប់ជីវ្ហាវិញ្ញាណ[30]ឆ្ងាញ់
សាច់ព្យាឧសត្វពុំចាញ់ សាច់ត្រីក្រាញ់រស់ជាតិផ្អែម។
បន្លែស្រស់និងក្រៀម ចំណីសៀមបូកបន្ថែម

22 ប្រស័យ : សេចក្តីស្នេហា។
23 អាស្រ័យ : ប្រព្រឹត្តទៅដោយសារ។
24 អក្ខោ : ច្រើនក្រៃ។
25 វល្លកា : ភរិយាដែលស្វាមីស្រឡាញ់ទុកចិត្តឥតរង្កៀស។
26 ជលី : ម្រាមដៃ។
27 គ្មានភ្លោះភ្លើយ : ដែលគ្មានគោះតើយប្រដើយ។
28 ល្មើយ : ទន់ដូចសំឡី។
29 ភក្សាហារ : ចំណីអាហារ។
30 ជីវ្ហាវិញ្ញាណ : សេចក្តីដឹងច្បាស់នូវរស់ជាតិដោយសារអណ្តាត។

## ឧត្តមតរិយា

ទុកជានុំបង្អែម ម្ហូបបន្លែងជីវ្ហា[31]ប៉ង។

អស់កូនមួយៗម្តង លាអូនបងដូរទីឋាន
ចេញពីគេហដ្ឋាន សាងគូប្រាណក្នុងជីវិត។
យើងលើកហត្ថបន់ស្រន់ ជាបំណន់ឱ្យមានរិទ្ធ
ឱ្យជួបផ្លូវពិសិដ្ឋ ក្នុងពុទ្ធព្រឹទ្ធ[32]រក្សាសុខ។

## ឧប្បត្តិហេតុ



បន់ស្រន់ទេវតា

ឆ្នាំកុរ-កន្លងទៅ ឆ្នាំស្រីពៅប្រទះទុក្ខ
ជាហេតុគួររន្ធត់ កាយវីរក់នឹងមហារីក។

31 ជីវ្ហា : អណ្តាត។
32 ពុទ្ធព្រឹទ្ធ : សេចក្តីចម្រើនប្រាជ្ញា។

# ឧត្តមភរិយា

ស្វាមីសែនអាណោច  វាមកស្រោចទុក្ខរលីក[33]
ចិត្តអាណិតផ្កាម្លិះ  មិនដែលរិះភក្ត្រញញឹម។

បងនាំស្ងួនទៅពេទ្យ  គេឃាត់ទេពទុកព្យាបាល
រោគវិនិច្ឆ័យពាល  ទងស្បួនរាលរោគពេញពោះ។
គ្រូពេទ្យសង្ឃឹមតិច  ដំណឹងក្តិចចិត្តជាគ្រោះ
បើគ្មានអ្វីសង្គ្រោះ  ពិតជាជ្រោះទុក្ខលន្លោច។

ទុក្ខនេះគឺឧត្បាត  វាព្យាបាទកាយនិងចិត្ត
ជាមហាទុក្ខជំរឹត  ដល់ចារិក[34]នៃនិវាស។
គ្មានពាក្យនឹងអាចថ្លែង  វាសំដែងហើយវាជ្រាស
ស្មាត់រកសព្វកន្លែង  ទីកន្លែងព្រលឹងស្រី។

ទឹកភ្នែកភរិយា  លើថ្ពាល់ទាររកដៃរាម
ដៃក្នុងដៃពុំស្ញៀម  ជាសំនៀងរួមភក្តី។
មានតែរូមតស៊ូ  ក្នុងពេលយូរប្តីបមបី

33 រលីក ៖ ដែលហើមឬប៉ោងឡើង។
34 ចារិក ៖ ន. ទីដែលជាទីត្រាច់ទៅឬទីត្រាច់។

## ឧត្តមភរិយា

រាល់ថ្ងៃរាល់រាត្រី   នៅក្បែរស្រីសុរូបា[35]។

ច្រើនខែពៅដេកពេទ្យ   បងនៅវៃទ្យ[36]លុះអាធ្រាត្រ
ឈឺណាស់ស្រីនួនល្អង   ភ្នែកស្រីស្ងួនស្វែងរកបង។
បងអើយពិបាកណាស់ !   ស្វាមីម្ចាស់ចិត្តអូនផ្សង
ឈឺជួនសន្លប់ផង   បងអាចសងពៅបែបណា ?

ឃើញអូនបាត់ស្មារតី   ចិត្តជាប្ដីទុក្ខគ្មានស្រាក
គិលានុបដ្ឋាក   ពុំសំរាករត់រកគ្រឿង។
បរិក្ខារគ្រប់គ្រាន់   ឱ្យបានទាន់គ្មានហត់នឿយ
ពុំកំរោះកំរើយ   ចិត្តត្រាណត្រើយ[37]ជួយអ្នកឈឺ។

ខែរងាឆ្លងផ្ការីក   ខ្យល់រំភើកភ្លៀងមកដល់
ភ្លៀងធ្លាក់ត្រជាក់ផ្ដល់   រដូវខ្យល់ពេទ្យប្រកាស។
ថាពៅមានសង្ឃឹម   ព្រោះរំពឹងថ្នាំអាចផ្សះ
ជាថ្នាំអាចនឹងឈ្នះ   ជ័យជំនះរោគចង្រៃ។

---

35 សុរូបា ៈ ស្ត្រីរូបល្អ។
36 វៃទ្យ ៈ គឺ ពេទ្យ ពាក្យសំស្ក្រឹត អានឭសូរជាស្រះអៃ ជួនឭសូរជាស្រះអេ។
37 ចិត្តត្រាណត្រើយ ៈ ចិត្តជាទីពំនាក់ទុកស្មើត្រើយ។

# ឧត្តមភរិយា

លើកហត្ថសំពះព្រះ   សូមឱ្យឈ្នះមារចង្រៃ
គុណព្រះរ័ត្នត្រៃ   និងអាស្រ័យអស់គ្រូពេទ្យ។
នឹកគុណដល់ព្រះគ្រូ   ជួយតស៊ូស្របនឹងទេព
ទេវតាគ្រប់ភេទ   ប្រើប្រភេទ ថម៌-វេជ្ជះ។

រួមយកជ័យលើរោគ  ជាថ្នាំរោមវាយព្យាធិ[38]ធំ
នាំសួស្តីឱ្យមុំ   ឱ្យពៅធំ[39]ជាស្រោកស្រាន្ត។
បំភ្លេចប្រាណស្លុតទ្រុឌ   ចិត្តប្រយុទ្ធគ្មានគិតស្មាន
ថាចាញ់កលឧបាយ   រោគប្រតាយកាយប្រផាក់។

## ប្រតិសន្ធិ



ភរិយា និង កូនប្រុសស្រី

[38] ព្យាធិ : ជម្ងឺ។
[39] ពៅធំ : ជាឈ្មោះ របស់ភរិយាខ្ញុំ ដែលម្តាយនាងដាក់អោយ។

# ឧត្តមតរិយា

ចាកផុតពីរោគា  គឺដូចគ្នាមេឃស្រឡះ
មានចន្ទចាំងក្នុងស្រះ  ឈប់ប្រទះនឹងពិធុរ។
អូនជាចន្ទចាកមេឃ  ចិត្តអរគ្រេកផ្សងសាធុ
ឱ្យចន្ទជួបវិមុត្តិ[40]  ឥតមានស្លុតវិលជួបបង។

វិលមករកសម្បុក  ជាឋានសុខទីថ្កើងថ្កាន
ជីវិតធ្លាប់កំសាន្ត  ក្នុងទីដ្ឋានជាគ្រួសារ។
កូនចៅសែនសប្បាយ  ទទួលម្ដាយស្មើទេវតា
ជុំគ្នាជួបជីវ៉ា  អោបកាយាអ្នកដាយ[41]ថ្លៃ។

ទោះបីប្រាណស្គមស្គាំង  តែមិនបាំងលោមណ៍[42]នាងនួន
ទោះជាកម្លាំងស្ទួន  មិនអាចជួន[43]នឹងមេផ្ទះ។
តែមានកូននិងបង  ផ្គាប់ផ្គងគ្រប់កិច្ចភត្តៈ[44]
ស្មោះសរដោយសច្ចៈ  ផ្ទះជាសគ្គ[45]លើលោកីយ។

---

[40] វិមុត្តិ ៈ ការរួចផុតស្រឡះ, ដំណើរមានឥស្សរភាព។
[41] អ្នកដាយ ៈ ជីដូន។
[42] លោមណ៏ ៈ ឆោម។
[43] ជួន ៈ កិ. គ្រប់គ្រាន់, ល្មម។
[44] កិច្ចភត្តៈ ៈ មកពីពាក្យ ភត្តកិច្ច, ការបរិភោគអាហារ។
[45] សគ្គ ៈ ឋានសួគ៌។

# ឧត្តមភរិយា

ពេលអាពាធវុដ្ឋាន[46] ស្រីចំណានភក្ត្របវរ
សោភ័នពៅនៅល្អ មិនមានក្រឆោមធម្មជាតិ។
បងរឹតតែគ្នាន់គ្នាញ់ រាមស្រឡាញ់ម្លឹងស្រីនាថ
គ្មានវាទានុវាទ[47] ចិត្តគិតវាសតែស្នេហា។

ស្នេហ៍ដើមនៅតែថ្មី ស្នេហ៍ភក្តីដូចសប្បថ
អូនបងប្រកាសស្បថ មិនកំសត់មុខមេឃុំ។
យើងនាំគ្នាស្បថថា ក្នុងបញ្ហាជីវិតខ្ញុំ
ល្អឬអាក្រក់សុំ តែយើងខ្ញុំរក្សាស្នេហ៍។

អូនម្ចាស់ជាទេពច្យុតិ[48] បងជាមនុស្សជាតិមានភ័ព្វ
ចតុត្ថៈ[49]សតវត្ស ជីវិតរាស់យកផលបុណ្យ។
ជីវិតរួមជាគ្រួ រួមជាតួអប់រំបុត្រ

---

46 អាពាវុដ្ឋាន : ភាពងើបពីឈឺ។
47 វាទានុវាទ : ពាក្យប្រកាន់និងពាក្យ។
48 ទេពច្យុតិ : ទេព្តាដែលឃ្លាតចាកទេវលោក។
49 ចតុត្ថៈ : មួយភាគបួន។

# ឧត្តមភរិយា

និងបុត្រីវិសុទ្ធ   មានចក្សុ[50]ធម៌ជាសើន[51]។

គន្លរឈ្មោះយាយតា   គ្មានប្រាថ្នាលោភទ្រព្យ
បញ្ចសីល[52]សុរក្ខា[53]   ជាសិលាពីព្រេងព្រឹទ្ធ។
អព្ភូតហេតុ[54]មានពិត   ជាសិខណ្ឌិន[55]ទេពនៃឫទ្ធិ
បាញ់អព្ភក្ស័យជីវិត   ពរប្រសិទ្ធឃើញចន្ទរះ។

ចាំងចែងជានិរន្ត   លើភក្រ្តគន់ល្អលើសលន់
ស្នេហ៍អូនជាទឹកមន្ត   ជាអាគមចងស្នេហ៍យើង។
ប្រណីពីជម្មជាតិ   ចិត្តឥតឃ្លាតឆ្ងិតតែភ្លើង
ស្នេហារបស់យើង   មិនរំលើងសម្មាចារ[56]។

ឧត្តមភរិយាបង   អូននិងបងមានសម្ភារ[57]

---

50 ចក្សុ : ភ្នែក។
51 សើន : Phare។
52 បញ្ចសីល : សីល៥។
53 សុរក្ខា : ការរក្សាដោយប្រពៃ។
54 អព្ភូតហេតុ : ហេតុអស្ចារ្យ។
55 សិខណ្ឌិន : ព្រួញ។
56 សម្មាចារ : ការប្រព្រឹត្តត្រូវឬល្អ។
57 សម្ភារ : ការសាងសន្សំកុសល។

# ឧត្តមភរិយា

នោះពិតជាទ្រព្យ   សំរាប់គ្រាវ័យចំណាស់។

នៅក្នុងចុងជីវិត   នៅស្មោះពិតទោះបីចាស់

រាមផ្សងត្រេងអរណាស់   ឱ្យជួបណាស់ពៅគ្រប់ជាតិ៚



ចំប៉ីដួងចិត្តប្ដី